N-26
15-7-02

# ក

# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ១.ព្រះរាជក្រម


០៨-៧-២០០២ -ព្រះរាជក្រម នស/រកម/០៧០២/០១១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ ស្តីពី គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ១៨៥៥


### ២.ព្រះរាជក្រឹត្យ


២៥-៥-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៥០២/១៣៧ ស្តីពីការប្រោសព្រះរាជទាន

**ក.**គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ០២រូប

**ខ.**គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ០៣ រូប ១៨៦៤

០៥-៧-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៧០២/១៧៨ ស្តីពីការ ប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **ឯម សំអាន** នូវ គ្រឿង ឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ១៨៦៥

០៦-៧-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៧០២/១៨១ ស្តីពីការតែងតាំងឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** ជានាយកសាលាភូមិន្ទនគរបាល នៃក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ១៨៦៦

០៨-៧-២០០២ -ព្រះរាជក្រឹត្យ នស/រកត/០៧០២/១៨២ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ស៊ិនមីង** (WANG SHEN MING)សញ្ជាតិដើមចិន កើតនៅកោះតៃវ៉ាន់ ប្រទេសចិន ១៨៦៧


## II.រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០៩-៧-២០០២ -អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ១៨៦៨

១០-៧-២០០២ -អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពីការតែងតាំងទីប្រឹក្សា ១៨៧០

១០-៧-២០០២ -អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៨៧១

១១-៧-២០០២ -អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ របស់មន្ត្រីរាជការ ១៨៧២

១១-៧-២០០២ -អនុក្រឹត្យលេខ ៣៣៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "**កម្ពុជា រ៉េ**" ១៨៧៣

១១-៧-២០០២ -អនុក្រឹត្យលេខ ៣៣៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អម ក្រុមហ៊ុនជាតិ ធានារ៉ាប់រងកម្ពុជា ១៨៧៤

១១-៧-២០០២ -អនុក្រឹត្យលេខ ៣៣៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨៧៥

១១-៧-២០០២ -អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨៧៦

១១-៧-២០០២ -អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៨៧៧

១២-៧-២០០២ -អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្តីពីការតែងតាំងនាយនគរបាលជាតិជាន់ខ្ពស់ ១៨៧៨

១២-៧-២០០២ -អនុក្រឹត្យលេខ ៣៤២ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១៨៨០

## III-ការងារបណ្តាក្រសួង

### ១-អន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១២-៧-២០០២ -ប្រកាសលេខ ៤៣២ សហវ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់រៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើ ១៨៨២

### ២-ក្រសួងពាណិជ្ជកម្ម

១២-៧-២០០២ -ប្រកាសលេខ ១៨៩ MoC/M 2002 ស្តីពីការលុបឈ្មោះពីសមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ១៨៨៥

# ព្រះរាជក្រម

នស/រកម/០៧០២/០១១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់

# ស្តីពី

# គណនេយ្យសហគ្រាស សវនកម្មគណនេយ្យ សហគ្រាស និងវិជ្ជាជីវៈគណនេយ្យ

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះកំណត់នូវការរៀបចំការគ្រប់គ្រង និងការប្រព្រឹត្តិទៅនៃប្រព័ន្ធគណនេយ្យជាលក្ខណៈអន្តរជាតិ សម្រាប់សហគ្រាសទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គលដែលមានវិជ្ជាជីវៈសេរី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ពាក្យ**គណនេយ្យ** ក្នុងច្បាប់នេះ គឺជាប្រព័ន្ធមួយដែលប្រើដើម្បីកំណត់កត់ត្រា ផ្តុំបញ្ចូលគ្នា វាស់វែង ចាត់ថ្នាក់និងបង្ហាញនូវពត៌មានហិរញ្ញវត្ថុ ដែលទាក់ទងនឹងសកម្មភាពនៃអង្គភាពមួយ ។

ពាក្យ**សវនកម្ម** នៅក្នុងច្បាប់នេះ គឺជាការត្រួតពិនិត្យឡើងវិញ ឬការត្រួតពិនិត្យប្រកបដោយលក្ខណៈជាប្រព័ន្ធ ទៅលើការអះអាង ឬលើសកម្មភាពរបស់អង្គភាពអាជីវកម្មមួយដើម្បីឱ្យអង្គភាពនោះគោរពតាមស្តង់ដារគណនេយ្យ ។ សេវាសវនកម្មរួមមាន សវនកម្ម របាយការណ៍ហិរញ្ញវត្ថុ សវនកម្មប្រតិបត្តិការ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ការពិនិត្យឡើងវិញ និងនីតិវិធីដែលបានព្រមព្រៀងគ្នា ។ សេវាករដែលអាចបម្រើសេវាទាំងនោះបាន និងអាចចុះហត្ថលេខាលើរបាយការណ៍ក្នុងនាមជាសវនករបាន លុះត្រាតែសវនករនោះបានចុះឈ្មោះក្នុងបញ្ជី ដោយអនុលោមទៅតាមច្បាប់នេះ ។

ពាក្យ**របាយការណ៍ហិរញ្ញវត្ថុ** នៅក្នុងច្បាប់នេះ គឺជារបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលនៃសកម្មភាពនានា និងពីចលនាសាច់ប្រាក់របស់អង្គភាពណាមួយ នៅក្នុងកាលបរិច្ឆេទជាក់លាក់មួយ ។

ពាក្យ **ស្តង់ដារគណនេយ្យអន្តរជាតិ** នៅក្នុងច្បាប់នេះ គឺជាស្តង់ដារប្រកាសឱ្យប្រើដោយក្រុមប្រឹក្សាភិបាលស្តង់ដារគណនេយ្យអន្តរជាតិ ។

**មាត្រា ៣.-**

គ្រប់សហគ្រាសជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវមានកាតព្វកិច្ចរៀបចំ និងកាន់បញ្ជីគណនេយ្យ ដោយអនុលោមទៅតាមច្បាប់ជាធរមាន និងត្រូវដាក់បញ្ជីគណនេយ្យនេះ ឱ្យមានការធ្វើសវនកម្ម ស្របទៅតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៤.-**

រៀងរាល់ឆ្នាំ គ្រប់សហគ្រាស ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យស្របតាមក្របខ័ណ្ឌទស្សនទាន និងតាមស្តង់ដារគណនេយ្យកម្ពុជា ដែលគោលការណ៍នានាត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមរបៀបស្តង់ដារគណនេយ្យអន្តរជាតិ។

**មាត្រា ៥.-**

គ្រប់សហគ្រាស ត្រូវកាន់បញ្ជីគណនេយ្យរបស់ខ្លួន នៅក្នុងសៀវភៅគណនេយ្យដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមរបៀបស្តង់ដារគណនេយ្យអន្តរជាតិ ។ រាល់ប្រតិបត្តិការគណនេយ្យត្រូវសំអាងលើឯកសារយុត្តិការ ។

## ជំពូកទី ២
## ក្រុមប្រឹក្សាជាតិគណនេយ្យ

**មាត្រា ៦.-**

ត្រូវបានបង្កើតឡើងនូវក្រុមប្រឹក្សាជាតិគណនេយ្យមួយ ដែលស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

សមាសភាពនិងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាជាតិគណនេយ្យមានភារកិច្ច :

- ធ្វើជាអង្គការពិគ្រោះយោបល់

- ពិនិត្យ និងផ្តល់យោបល់លើរាល់គម្រោងច្បាប់និងបទបញ្ញានានាដែលមានបទប្បញ្ញត្តិទាក់ទងទៅនឹងការរៀបចំកិច្ចការគណនេយ្យសម្រាប់រាល់សហគ្រាស ឬសកម្មភាពសេដ្ឋកិច្ច

- រៀបចំក្របខ័ណ្ឌទស្សនទាននិងស្តង់ដារគណនេយ្យ ដូចមានចែងនៅក្នុងមាត្រា ៤ នៃច្បាប់នេះ

- ស្នើឡើងនូវមធ្យោបាយសម្រាប់កែលំអបច្ចេកទេសគណនេយ្យ

- ធ្វើជាតំណាងព្រះរាជាណាចក្រកម្ពុជានៅក្នុងអង្គការអន្តរជាតិ និងនៅក្នុងកិច្ចប្រជុំដើម្បីជជែកវែកញែកអំពីគណនេយ្យ ។

## ជំពូកទី ៣

## របាយការណ៍ហិរញ្ញវត្ថុ

**មាត្រា ៨.-**

របាយការណ៍ហិរញ្ញវត្ថុរួមមាន តារាងតុល្យការ របាយការណ៍លទ្ធផល តារាងចលនាសាច់ប្រាក់ និងកំណត់សម្គាល់ ។ របាយការណ៍ទាំងអស់នេះ ជាឯកសាររួមប្រចាំឆ្នាំ ដែលមិនអាចញែកចេញដាច់ពីគ្នាបានឡើយ ។

**មាត្រា ៩.-**

សៀវភៅគណនេយ្យដែលបានចែងនៅក្នុងមាត្រា ១២ ត្រូវបានរៀបចំជាភាសាខ្មែរ និងជាប្រាក់រៀល ។ សហគ្រាសទាំងឡាយណាបំពេញកិច្ចប្រតិបត្តិការជាមួយបរទេស ឬជាសាខានៃក្រុមហ៊ុនបរទេស អាចអនុញ្ញាតឱ្យរៀបចំសៀវភៅគណនេយ្យជាភាសាអង់គ្លេសអមជាមួយ ឬនិងជារូបិយវត្ថុផ្សេងពីប្រាក់រៀល ស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក៏ប៉ុន្តែរបាយការណ៍ហិរញ្ញវត្ថុ ដូចបានបញ្ជាក់នៅក្នុងមាត្រា ៤ គឺត្រូវរៀបចំជាភាសាខ្មែរ និងជាប្រាក់រៀល ។

មាត្រា ១០.-

រយៈពេលនៃការិយបរិច្ឆេទគណនេយ្យមានកម្រិតដប់ពីរខែ ។ ការិយបរិច្ឆេទនេះ ចាប់ផ្តើមពីថ្ងៃទី ១ ខែ មករា និងបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ក្នុងឆ្នាំដដែល ។ ចំពោះសហគ្រាសបង្កើតថ្មី របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់ឆ្នាំទី ១ ចាប់ផ្តើមពីថ្ងៃបង្កើត នឹងបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំបន្ទាប់ ។ អាចកំណត់បាននូវកាលបរិច្ឆេទមួយដោយឡែកសម្រាប់សកម្មភាពដែលមានលក្ខណៈពិសេស ។

មាត្រា ១១.-

របាយការណ៍ហិរញ្ញវត្ថុ ត្រូវរៀបចំយ៉ាងយូរបំផុតក្នុងរយៈពេលបីខែ បន្ទាប់ពីថ្ងៃបិទការិយបរិច្ឆេទ ។ ប្រសិនបើសហគ្រាសណាមួយ មិនអាចគោរពតាមពេលវេលានេះបានទេ សហគ្រាសនោះ ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវការអនុញ្ញាតលើកពេលបិទបញ្ជី និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុទៅកាលបរិច្ឆេទមួយផ្សេងទៀតបាន ។

មាត្រា ១២.-

របាយការណ៍ហិរញ្ញវត្ថុ ដែលទាក់ទងនឹងកិច្ចការគណនេយ្យ ព្រមទាំងសៀវភៅ និងឯកសារយុត្តិការនានាដែលពាក់ព័ន្ធ ត្រូវរក្សាទុកក្នុងរយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងតិច ។ សៀវភៅទាំងនេះរួមមាន ទិនានុប្បវត្តិ សៀវភៅធំ និងសៀវភៅសារពើភណ្ឌ ។

មាត្រា ១៣.-

របាយការណ៍ហិរញ្ញវត្ថុ និងសៀវភៅគណនេយ្យនានា ដែលបានចែងនៅក្នុងមាត្រា ១២ នៃច្បាប់នេះ អាចទទួលស្គាល់ជាផ្លូវការបាន លុះត្រាតែរបាយការណ៍ និងសៀវភៅទាំងនោះ មានភាពស្របទៅនឹងបញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

## ជំពូកទី ៤

## វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករ

**មាត្រា ១៤.-**

ត្រូវបានបង្កើតវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករក្នុងចំណោមអ្នកមានវិជ្ជាជីវៈគណនេយ្យ ។ វិទ្យាស្ថាននេះនឹងប្រព្រឹត្តទៅក្រោមអាណាព្យាបាលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃវិទ្យាស្ថានព្រមទាំងការរៀបចំក្រមសីលធម៌នៃវិជ្ជាជីវៈគណនេយ្យករជំនាញនិងសវនករ និងការចុះឈ្មោះក្នុងបញ្ជីប្រតិស្រុតដាច់ដោយឡែកពីគ្នានៃគណនេយ្យករជំនាញនិងសវនករ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥.-**

វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករ ត្រូវបានបង្កើតឡើងដើម្បី :

- ផ្តល់ជូនអង្គភាពវិជ្ជាជីវៈមួយដែលទទួលខុសត្រូវជាតំណាងឱ្យសមាជិករបស់ខ្លួន ព្រមទាំងលើកតម្កើងនិងការពារលក្ខន្តិកៈ និងផលប្រយោជន៍នៃវិជ្ជាជីវៈគណនេយ្យ
- ចូលរួមបំពេញការងារជាសមាជិកនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- រៀបចំនិងធ្វើឱ្យមានការគោរពវិធាន និងកាតព្វកិច្ចនៃវិជ្ជាជីវៈ
- រៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈគណនេយ្យនិងសវនកម្មដល់ប្រជាពលរដ្ឋខ្មែរដែលជ្រើសរើសយកអាជីពទាំងពីរនេះ ។

## ជំពូកទី ៥

## សវនកម្មគណនេយ្យសហគ្រាស

**មាត្រា ១៦.-**

គ្រប់សហគ្រាសជារូបវន្តបុគ្គល ឬនីតិបុគ្គលត្រូវដាក់បញ្ជីគណនេយ្យរបស់ខ្លួនឱ្យមានការត្រួតពិនិត្យដោយសវនករឯករាជ្យ ក្នុងករណីដែលចំនួនទឹកប្រាក់នៃផលរបរ ឬនិងចំនួនពិតសរុបរបស់តុល្យការ ឬនិងចំនួននិយោជិតរបស់ខ្លួនមានលើសពីកំរិតដែលបានកំណត់ដោយ

ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការងារសវនកម្មត្រូវបំពេញដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានចុះឈ្មោះក្នុងបញ្ជីប្រតិស្រុត ដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

## ជំពូកទី ៦
## វិជ្ជាជីវៈគណនេយ្យ

**មាត្រា ១៧.-**

ការបំពេញវិជ្ជាជីវៈជាគណនេយ្យករជំនាញ ត្រូវសម្រេចដោយរូបវន្តបុគ្គល ឬនីតិ-បុគ្គលដែលបានចុះឈ្មោះក្នុងបញ្ជីប្រតិស្រុត ដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

ការបំពេញវិជ្ជាជីវៈគណនេយ្យករជំនាញ មានវិសមិតភាពជាមួយមុខងារសាធារណៈ និងមុខងារនយោបាយក្នុងអង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ១៨.-**

រូបវន្តបុគ្គល និងអ្នកដឹកនាំនៃអង្គភាពនីតិបុគ្គល ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃមាត្រា ៣ មាត្រា ៤ និងមាត្រា ៥ នៃច្បាប់នេះ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល ឬនិងត្រូវជាប់ពន្ធនាគារ ពី ១(មួយ)ឆ្នាំ ទៅ ២(ពីរ)ឆ្នាំ ។ រូបវន្តបុគ្គល និងអ្នកដឹកនាំនៃអង្គភាពនីតិបុគ្គលដែលពុំបានធ្វើរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវ ឬខកខានពុំបានធ្វើរបាយការណ៍ហិរញ្ញវត្ថុ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល ឬ និងជាប់ពន្ធនាគារពី ៣ (បី)ខែ ទៅ ៦ (ប្រាំមួយ)ខែ ។

ក្រៅពីការផ្តន្ទាទោសខាងលើ រូបវន្តបុគ្គលនិងអ្នកដឹកនាំនៃអង្គភាពនីតិបុគ្គលត្រូវលុបឈ្មោះចេញពីបញ្ជីប្រតិស្រុត ។ ល័ក្ខខ័ណ្ឌនៃការលុបឈ្មោះចេញពីបញ្ជីប្រតិស្រុត នឹងមានចែងនៅក្នុងអនុក្រឹត្យ ។

មាត្រា ១៩.-

គណនេយ្យករជំនាញ និងសវនករ ដែលពុំបានគោរពទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ នឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីមិនរាងចាលនឹងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទ្វេដង ឬនិងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៣(បី)ឆ្នាំ ដោយមិនទាន់គិតដល់ការលុបពីបញ្ជីប្រតិស្រុតឡើយ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

មាត្រា ២០.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០០២

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

នស/រកម-០៧.០៧.០០១៨៦

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ហត្ថលេខា**

**គាត ឈន់**

លេខ: ១៥៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ទី [illegible]**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០២/១៣៧

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

ទ្រង់ប្រោសព្រះរាជទាន

ក- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ចំពោះ :

១- លោក **ជឹម ផាន**

២- លោក **សាក់ ឡុង**

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

១- លោក **អ៊ិន សុខអេង**

២- លោក **គឹម វណ្ណា**

៣- លោក **អ៊ុន ចេក**

**ព្រះហស្ដលេខា និង ព្រះរាជលញ្ឆករ**

**នរោត្ដម សីហនុ**

ពរល.០២.០៥.០០១៤៧

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០០២*

លេខ [illegible] ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] ណារ៉ាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០២/១៧៨

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម **ឯម សំអាន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

៣រល.០៧.០៧.០០១៨៨

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០២*

លេខ :១៥៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

## យើង

នស/រកត/០៧០២/១៨១

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់តាមសេចក្ដីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

**មាត្រា១ .-** ត្រូវបានតែងតាំងឯកឧត្តមនាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គលេខ ០០៤ អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ជានាយកសាលាភូមិន្ទនគរបាល នៃក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន។

**មាត្រា២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

លេខ : [illegible] ច.ល

ដើម្បីចម្លងចែក

៣រស-០២.០៧.០០១៩១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០២

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៧០២/១៨២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **វ៉ាង ស៊ិនម៉ីង** ( WANG SHEN MING ) សញ្ជាតិដើមចិន កើតថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៣៩ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា និង ព្រះរាជលញ្ជករ**

**នរោត្តម សីហនុ**

លេខ : ១៥៥ច.ល

៣៩ល.០២.០៧.០០១៩២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ អាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..៦៦...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ . ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.៥០០ លានរៀល ( មួយពាន់ប្រាំរយលានរៀលគត់ ) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សម្ភារៈ និង ការជួសជុលតូច ) របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់របបជីវភាព និងសម្ភារៈបីមុខ របស់ទណ្ឌិត ពិរុទ្ធជន។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

A2.doc

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៣៣ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងទីប្រឹក្សា

*******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក ឈុប អាន ជាទីប្រឹក្សាបច្ចេកទេសអមរដ្ឋមន្ត្រី ក្រសួងបរិស្ថាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ[illegible] ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៣៤ អនក្រ.បក-៩៩

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * * * * * * * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់ និងសាធារណការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**សំ រេ ច**

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **កែវ លាប** ជានាយកមន្ទីរពិសោធន៍សំណង់ និងសាធារណការ នៃក្រសួងសាធារណការនិងដឹកជញ្ជូន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមុីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ របស់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**<u>មាត្រា ១</u>** : ត្រូវបានផ្លាស់ប្តូរកន្លែងធ្វើការ ដល់មន្ត្រីរាជការចំនួន ០២រូប នៅខេត្តកោះកុង ដូចមានរាយនាមខាងក្រោម :

១-លោក **សោម សុធីរ** អភិបាលស្រុកមណ្ឌលសីមា អោយមកជាអភិបាលស្រុកស្រែអំបិល

២-លោក **មឿង លួនសា** អភិបាលស្រុកស្រែអំបិល អោយមកជាអភិបាលស្រុកមណ្ឌលសីមា

**<u>មាត្រា ២</u>** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**<u>មាត្រា ៣</u>** : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ អភិបាលខេត្តកោះកុង និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>ចម្លងជូន</u>** :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "<u>ដើម្បីអនុវត្ត</u>"*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រ៉ េ "

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រ៉េ "

-យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំ រេ ច

**មាត្រា១:**តែងតាំងលោក **នេត មុន្នី** អនុប្រធានទី១នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រ៉េ " ។

**មាត្រា២:**ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា " កម្ពុជា រ៉េ "

-ដូចមាត្រា២

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៣៣៧.អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពីការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋ អមក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ស្ដីពីការបង្កើតក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ស ម្រេ ច

**មាត្រា១:** តែងតាំងលោក **សាន់ សារោ** អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា ។

**មាត្រា២:** ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **URIEL NORMAN R. GARIBAY** លេខាធិការទី ២ និងជាកុងស៊ុលទទួលបន្ទុកយោធា នៃស្ថានទូតហ្វីលីពីន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញភារកិច្ច នៅកម្ពុជា រយៈពេល ០៣ ឆ្នាំ ០១ ខែ ប្រកបដោយស្នាដៃល្អ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៣៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សរិទ្ធិ** ជូនលោកវរនាវីឯក **YURY KOBYLYATSKIY** សេនានុពន្ធអមស្ថានទូតសហព័ន្ធ រុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញភារកិច្ច នៅកម្ពុជា រយៈពេល ០៣ ឆ្នាំ ប្រកបដោយស្នាដៃល្អ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៧៤០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

៚៚៚៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនលោកវរសេនីយ៍ត្រី **Marc PINEAU** សេនានុពន្ធអមស្ថានទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានមកបំពេញភារកិច្ចនៅកម្ពុជា រយៈពេល ០៣ ឆ្នាំ ១៩ ថ្ងៃ ប្រកបដោយស្នាដៃល្អ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងនាយនគរបាលជាតិជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/ ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ/បក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការបង្កើតសាលាភូមិន្ទនគរបាល
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងមុខតំណែងនាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **សូរ ឆន** អត្តលេខ ០០៦ អគ្គស្នងការរងទី ១ នៃ អគ្គស្នងការដ្ឋាននគរបាល-ជាតិ ជានាយករងសាលាភូមិន្ទនគរបាល នៃក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២-លោកឧត្តមសេនីយ៍ត្រី **ម៉ា ឈឿន** អត្តលេខ ០០៨៨ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិង វិក្រឹតការ ជានាយករងសាលាភូមិន្ទនគរបាល នៃ ក្រសួងមហាផ្ទៃ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣-លោកវរសេនីយឯក **សារ៉ាន គឹមសត់** អត្តលេខ ០២០៧ បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននគរបាលសេដ្ឋកិច្ច ទៅជាប្រធានមន្ទីរចាត់ការ នៃសាលាភូមិន្ទនគរបាលក្រសួងមហាផ្ទៃ។

៤-លោកវរសេនីយ៍ឯក **ជា គីមលី** អត្តលេខ ០២៩៣ បច្ចុប្បន្ន អនុប្រធានសេនាធិការដ្ឋាន ទៅជា - ប្រធានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលដំបូង នៃ សាលាភូមិន្ទនគរបាលក្រសួងមហាផ្ទៃ ។

៥-លោកវរសេនីយ៍ឯក **ប្រាក់ សំអាត** អត្តលេខ ០៣១៥ បច្ចុប្បន្ន អនុប្រធានអធិការដ្ឋានកិច្ចការនគរបាល នៃ អគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និង នគរបាល ទៅជាប្រធានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលបន្ត និង ស្រាវជ្រាវ នៃ សាលាភូមិន្ទនគរបាលក្រសួងមហាផ្ទៃ ។

**មាត្រា២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ. ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*<u>កន្លែងទទួល</u>*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៤២ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១ :** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរៈសេនីយ៍ទោ **ឯម សំណាង** អត្តលេខ ០៩៧៩ អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២- លោកវរៈសេនីយ៍ទោ **ហ៊ូ សេងលន់** អត្តលេខ ០៦៥៩ អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ។

៣- លោកវរៈសេនីយ៍ទោ **ហាយ ច៉ារុន** អត្តលេខ ០៧២៩ អនុប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់ ។

៤- លោកវរៈសេនីយ៍ទោ **ចន្ទី សុវណ្ណ** អត្តលេខ ០៩៣៥ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង កាពារអនីតិជន ។

៥- លោកវរៈសេនីយ៍ទោ **នួច ចឹម** អត្តលេខ ០២២៨៨ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង កាពារអនីតិជន ។

៦- លោកវរៈសេនីយ៍ទោ **គឹម នាព** អត្តលេខ ០២២៨៩ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង កាពារអនីតិជន ។

៧- លោកវរៈសេនីយ៍ទោ **ឆុយ ចន្ថា** អគ្គលេខ ០៦៣៨ អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង កាពារអនីតិជន ។

៨- លោកវរៈសេនីយ៍ទោ **សូ សាន្ថ** អគ្គលេខ ០២០៤៨ អនុប្រធានសេនាធិការដ្ឋាន ។

៩- លោកវរៈសេនីយ៍ទោ **សួន ផល្លី** អគ្គលេខ ០៣៣៤៧ អនុប្រធានការិយាល័យកណ្តាលនគរបាលអន្តរជាតិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

******

អន្តរក្រសួង

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៤៣២ សហវ

ភ្នំពេញ , ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២

## ប្រកាសអន្តរក្រសួង

## ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងសំរាប់រៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើ

*****

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញច្បាប់អំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញតំរូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងសំរាប់រៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើ ដើម្បីពិនិត្យនិងរៀបចំឡើងវិញនូវប្រព័ន្ធចំណូលពីវិស័យព្រៃឈើកម្ពុជា ។

**ប្រការ ២ :** គណៈកម្មការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើមានសមាសភាពដូចខាងក្រោម :

- លោក ញិប ច័ន្ទថេត ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាប្រធាន
- លោក នេត មុន្នី អនុប្រធានទី ១ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធាន
- លោក ខួង ប៊ុននី អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក
- លោក វណ្ណ សំណាង ប្រធានការិយាល័យនៃនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក
- លោក ស៊ុំ សុខុន ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក
- លោក ឆេង គីមស៊ុន ប្រធានការិយាល័យកិច្ចការព្រៃឈើនៃនាយកដ្ឋាន រុក្ខា-ប្រមាញ់ ជាសមាជិក
- លោក ថន សារ៉ាត អនុប្រធានការិយាល័យផែនការ គណនេយ្យ នៃនាយកដ្ឋានរុក្ខា-ប្រមាញ់ ជាសមាជិក ។

**ប្រការ ៣ :** គណៈកម្មការរៀបចំប្រព័ន្ធគ្រប់គ្រងចំណូលព្រៃឈើមានភារកិច្ចពិនិត្យឡើងវិញនូវនីតិវិធី ក្នុងការប្រមូលចំណូលសួយសារឈើឈរ និង រាល់ចំណូលព្រៃឈើផ្សេងៗទៀត ព្រមទាំងនីតិវិធីដែលពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូល ដូចជា ការរៀបចំផែនការ កត់ត្រាចំណូល ធ្វើរបាយការណ៍ ផ្សព្វផ្សាយ និង សវនកម្ម ជាដើម ។

**ប្រការ ៤ :** គណៈកម្មការអន្តរក្រសួងនេះ :

-ត្រូវរៀបចំទំរង់របាយការណ៍ជាស្តង់ដាជាភាសាខ្មែរ និង អង់គ្លេសនូវរាល់ប្រតិបត្តិការប្រចាំឆ្នាំអោយបានលំអិតស្តីពីការគ្រប់គ្រងចំណូលសួយសារ និង ចំណូលព្រៃឈើផ្សេងៗទៀត

-ត្រូវរៀបចំផែនការលំអិតសំរាប់ណែនាំស្តីពីនីតិវិធីដែលបានស្នើឡើង ក្នុងនោះរួមមាន ការប៉ាន់ស្មានលើតំរូវការ និង ផ្គត់ផ្គង់សំភារៈការិយាល័យ សំរាប់នាយកដ្ឋានរុក្ខា-ប្រមាញ់ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ កិច្ចការនេះត្រូវដាក់បញ្ចូលក្នុងផែនការលទ្ធកម្មរបស់គំរោងធនាគារពិភពលោក ដែលផ្តល់ហិរញ្ញប្បទាន សំរាប់ "គំរោងការគ្រប់គ្រង និង ត្រួតពិនិត្យព្រៃសម្បទានគំរូ"

-ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាល និង ផ្តល់ការយល់ដឹងសំរាប់មន្ត្រីនាយកដ្ឋានរុក្ខាប្រមាញ់ មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងបុគ្គលិកក្រុមហ៊ុនព្រៃសម្បទាន

-ត្រូវរៀបចំសេចក្តីព្រាងណែនាំដើម្បីអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ផ្សព្វផ្សាយជាផ្លូវការនូវសំណើសុំរបស់គណៈកម្មការ និង អាចសុំការអនុម័តបន្ថែមទៀតចំពោះករណីចាំបាច់ (សុំការយល់ព្រមពីទីស្តីការគណៈរដ្ឋមន្ត្រី)

-ធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ លើផ្នែកចាំបាច់មួយនៃការងាររបស់ខ្លួន ហើយត្រូវធ្វើរបាយការណ៍ ដាក់ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រឹមថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០២ ។

**ប្រការ ៥** : រាល់ការចំណាយលើការងាររបស់គណៈកម្មការនេះ នឹងត្រូវទូទាត់ចំណាយជាក្រោយ ពីគំរោងការគ្រប់គ្រង និង ត្រួតពិនិត្យព្រៃសម្បទានគំរូ ដែលហិរញ្ញប្បទានដោយធនាគារពិភពលោក ។

**ប្រការ ៦** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៧** : ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ចន្ទ សារុន

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៤៨ MoC / M 2002

# ប្រកាស
## ស្តីពីការលុបឈ្មោះពីសមាជិកជ្រើសតាំង សភាពាណិជ្ជកម្មរាជធានីភ្នំពេញ

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.ប្រក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភំពេញ

-បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.ប្រក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៩៨ ស្តីពីការកែប្រែមាត្រា ២ នៃអនុក្រឹត្យស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.ប្រក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.តត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

-យោងតាមសំណើរបស់លោកឧកញ៉ា ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

-តាមស្មារតីអង្គប្រជុំនៅសភាពាណិជ្ជកម្មរាជធានីភ្នំពេញ នាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០២

## សំ រេ ច

ប្រការ១: ត្រូវបានលុបឈ្មោះចេញពីសមាជិកជ្រើសតាំង នៃសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដោយមូលហេតុផ្សេងៗគ្នា នូវអស់លោកដែលមានរាយនាមដូចខាងក្រោមនេះ :

**- មិនបានចូលរួមប្រជុំរយៈពេល១ឆ្នាំ និងមិនបានបង់វិភាគទានចំនួន ១,២០០ ដុល្លារ:**

១-លោក **គឹម វ៉ាន់ឌី** សមាជិកជ្រើសតាំង ប្រភេទពាណិជ្ជកម្ម

**- មានភាពមិនប្រក្រតីដោយបែបបទពន្ធដារមានមិនគ្រប់គ្រាន់:**

១-លោក **គឹម ឡុង** សមាជិកជ្រើសតាំង ប្រភេទឧស្សាហកម្ម សិប្បកម្ម

២-លោក **ចាន់ វ៉េន** សមាជិកជ្រើសតាំង ប្រភេទសេវាកម្មនិងវិជ្ជាជីវៈសេរី

៣-លោក **តឹក ឌ៉ូយ** សមាជិកជ្រើសតាំង ប្រភេទកសិកម្ម

៤-លោក **កែវ មាស** សមាជិកជ្រើសតាំង ប្រភេទកសិកម្ម

៥-លោក **អ៊ុក ឃុន** សមាជិកជ្រើសតាំង ប្រភេទកសិកម្ម

ប្រការ២ : បទបញ្ញត្តិ និងសេចក្តីសំរេចទាំងឡាយ ដែលមានពីមុនមក មានន័យផ្ទុយពីប្រកាសនេះ ចាត់ទុកជានិរាករណ៍ ។

ប្រការ៣ : នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ និងសាមុីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០២

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាក្រុងភ្នំពេញ
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426306